# របៀបសរសេរ និង របៀបប្រើភាសាខ្មែរឱ្យបានត្រឹមត្រូវ

(ដកស្រង់ពីវចនានុក្រមខ្មែររបស់សម្ដេច ជួន-ណាត)

១-កង្វល់ (សេចក្ដីខ្វល់ចិត្ត ខ្វល់គំនិត)

- ខ្ញុំមានកង្វល់ , ស្រុកកើតកង្វល់
- កុំប្រើថាៈ ខ្ញុំមានសេចក្ដីកង្វល់ , ស្រុកកើតការកង្វល់ (ទំ.៥)

២-កុហក (និយាយឱ្យគេភាន់ជំនឿ)

- កុំកុហកគេ
- កុំប្រើថាៈ កហក់ ឬ ក្រហក់ (ទំ.៤៤)

៣-កំណួច (ការក្ដួច , ចំណងដែលចងក្ដួច)

- កំណួចស្មៅ , កំណួចខ្សែ ,លាក់កំណួច
- កុំសរសេរជាៈ កំនួច (ទំ.៥៥)

៤-ក្បិតក្បៀត (សំចៃ , សំចៃសំចៃ , មិនកញ្ជះកញ្ជាយ)

- ត្រូវខំក្បិតក្បៀតប្រាក់កាសកុំចាយវាយកញ្ជះកញ្ជាយពេក
- កុំប្រើថាៈ ត្បិតត្បៀត (ទំ.៦៩)

៥-ក្រិស (តូចច្រមិច)

- មនុស្សក្រិស , ក្មេងក្រិស , ស្វាក្រិស
- កុំសរសេរជាៈ ក្រិះ , ក្រេះ , ក្រែះ (ទំ.៨៥-៨៨)

៦-គង់វង្ស (គង់ពូជវង្សនៅមិនសូន្យ)

- យើងត្រូវរក្សាប្រពៃណីល្អឱ្យគង់វង្ស
- កុំសរសេរជាៈ គង់វង់ (ទំ.១២៤)

៧-គម្រប់ (ធ្វើឱ្យគ្រប់ , បង្គ្រប់ , បំពេញឱ្យគ្រប់)

- កុំសរសេរៈ គំរប់
- ត្រូវសរសេរៈ គម្រប់ (ដើម្បីឱ្យមានន័យទៀងទាត់តាមលក្ខណៈ វេយ្យាករណ៍ខ្មែរ) (ទំ.១៣០)

៨-គាថា (កម្រងវាចា , មាសឬប្រាក់ដែលចារបញ្ចុះគាថាយ័ន្តសម្រាប់ដាក់

ខ្សែចង្កេះ ខ្សែ ក ឬ ខ្សែដៃតាមទម្លាប់មនុស្សដែលធ្លាប់និយមរាប់អាន)

- គាថាពាន់ , គាថាពន្ធ
- កុំប្រើថា: កថា ឬ កាថា (ទំ.១៣២)

៩-គិរីវង់ (ឈ្មោះស្រុកមួយក្នុងខេត្តតាកែវ)

- ស្រុកគិរីវង់
- កុំសរសេរថា: គិរីវង្ស (ទំ.១៣៤)

១០-គួទ (តពោក ឬ ត្រពោក)

- ដាក់គួទអង្គុយ
- កុំសរសេរថា: គូថ ឬ គួធ (ទំ.១៣៨)

១១-ឆទានសាលា (សាលាសម្រាប់ចែកទានដល់ពួកស្មូម)

- កុំប្រើថា: សាលាឆទាន (ទំ.២២៦)

១២-ជើង (ឈ្មោះទិសមួយផ្ទុយពីទិសខាងត្បូង , ទិសឧត្តរ)

- កុំប្រើថា: ជើង ត្បូង កើត លិច
- ត្រូវប្រើថា: ខាងជើង ខាងត្បូង ខាងកើត ខាងលិច ឬ ឯជើង ឯត្បូង ឯកើត ឯលិច គឺត្រូវប្រើ ពាក្យ (ខាង ឬ ឯ)ផ្សំផងជាដរាប (ទំ.២៦៥)

១៣-ញៀតស្បាត (ដែលញឹកជ្រៀតជុកជិតដោយស្មៅឬស្បូវនិងឈើតូចៗ)

- ព្រៃញៀតស្បាត
- កុំសរសេរថា: ញាតស្បាត (ទំ.២៩៦)

១៤-ញុំាង (ប្រើ , បង្គាប់)

- គ្រូញុំាងសិស្សឱ្យរៀន , ញុំាងចិត្តឱ្យជ្រះថ្លា
- កុំប្រើថា: គ្រូញុំាងឱ្យសិស្សរៀន , ញុំាងឱ្យចិត្តជ្រះថ្លា (ទំ.២៩៨)

១៥-តម្កុល (ចាស់ព្រួលៗ ស្រោលៗ ឆ្អិនខ្លះឆៅខ្លះ)

- មនុស្សចាស់តម្កុល , គំនិតតម្កុល , ត្រីអាំងតម្កុល
- កុំប្រើថា: ដំពុល , តំពុល ,ទំពុល (ទំ.៣៣៨)

១៦-តម្លក់ (ប្រដាប់ធ្វើដោយដែកឬឈើ មានចុងរាងខ្វេរខុបសម្រាប់ថ្លក់ទាញអ្វីៗ)

- តម្លក់រនាស់
- កុំសរសេរជា: ទំពក់ (ទំ.៣៣៨)

១៧-តម្លែក (ដែលមានក្បាលថ្លែក , ដែលឥតសក់ ឬ រលីងដុំៗ)

- តម្លែកទាំងបួននាក់
- កុំសរសេរជា: ទំពែក (ទំ.៣៣៨)

១៨-ប្រុសស្រី និង បុរសស្ត្រី

- ប្រុសស្រី ជាប្ដីប្រពន្ធ
- បុរសស្ត្រី ជាស្វាមីភរិយា
- ត្រូវប្រើថា: ប្រុសស្រី ឬ ស្រីប្រុស
  បុរសស្ត្រី ឬ ស្ត្រីបុរស
- កុំប្រើថា: បុរសស្រី ឬ ស្ត្រីប្រុស (ទំ.៣៨៧-៦៨២-១៤៤០-១៤៨០)

១៩-នានា (ផ្សេងៗ , ទីទៃៗ)

- កុំសរសេរ: នាៗ (ទំ.៥០៣)

២០-បណ្ណាការ (ជំនូន , តង្វាយ)

- រៀបបណ្ណាការ
- កុំប្រើថា: បណ្ដាការ (ទំ.៥៤៥)

២១-ពន្លឹក (ដែលគួរភ្លឹក , គួរស្មឹម)

- កាចពន្លឹក , ភ័យពន្លឹក
- កុំប្រើថា: អរពន្លឹក , សប្បាយពន្លឹក (ព្រោះពុំមែនជាហេតុគួរឱ្យភ្លឹក
  ឱ្យភ្លេច ឱ្យស្លន់ភាំងគំនិតទេ) (ទំ.៧៣០)

២២-ពោធិសាត់ (ឈ្មោះខែត្រមួយក្នុងកម្ពុជរដ្ឋ នៅជាខាងកើតខែត្របាត់ដំបង)

- ខែត្រពោធិសាត់ , ក្រួចពោធិសាត់
- កុំសរសេរថា: ខែត្រពោធិសត្វ , ក្រូចពោធិសត្វ (ទំ.៧៨០)

២៣-មរតក (បុគ្គលដែលស្លាប់ហើយ)

- ទ្រព្យមរតក , ទទួលមរតក
- កុំសរសេរជា: មរដក (ទំ.៨៥៧)

២៤-ម៉ុម (ក្រមុំ , នាងក្រមុំ , ពាក្យថ្នមឬទំយើសម្រាប់ហៅស្ត្រីជាទីស្រឡាញ់)

- ម៉ុមបង , មាសម៉ុម , ស្រីម៉ុម
- កុំសរសេរថា: មុំបង , ស្រីមុំ (ទំ.៨៩៩)

២៥-លុប (ធ្វើឱ្យបាត់ស្នាម ឱ្យបាត់គំនូស ឱ្យបាត់រូប ឱ្យបាត់ឈ្មោះ ឱ្យវិនាស)

- លុបអក្សរ លុបឈ្មោះ លុបគុណ
- កុំសរសេរជា: លប់ (ទំ.១១០៩)

២៦-វ៉ៃធ (ជួសឆ្អឹះខ្លាំងដោយចុងស្នែង)

- ក្របីវ៉ៃធ
- កុំសរសេរជា: វ៉ាត់ (ទំ.១១៥៩)

២៧-វាងវៃ (ឈ្លាសវៃ , ដែលដឹងផ្លូវដឹងឧបាយ)

- ប្រាជ្ញាវាងវៃ , មនុស្សវាងវៃ
- កុំសរសេរជា: វៀងវៃ (ទំ.១១៦៧)

២៨-សម្បុរ និង ព័ណ៌ (សម្បុរ ប្រើចំពោះមនុស្សនិងសត្វនិករទាំងពួង ,

ព័ណ៌ ប្រើចំពោះតែសម្បុរនៃវត្ថុផ្សេងៗមានសំពត់ជាដើម)

- កុំនិយាយថា: មនុស្សព័ណ៌សណ្តែកបាយ , គោព័ណ៌ត្នោត
- ត្រូវនិយាយថា: មនុស្សសម្បុរសណ្តែកបាយ , គោសម្បុរត្នោត (ទំ.៧២៦-១២៩២)

២៩-សំណព្វ (ដែលពេញសព្វគ្រប់ក្នុងចិត្ត ,ដែលគាប់ចិត្ត , ដែលឥតមានទាស់អធ្យាស្រ័យ)

- កូនសំណព្វ , សិស្សសំណព្វ , ប្រពន្ធសំណព្វ
- កុំសរសេរជា: សំណប់ (ទំ.១៤១៨)

៣០-ហហ្មុក (ឈ្មោះម្ហូបមួយប្រភេទធ្វើដោយត្រីស្រស់ផ្សំគ្រឿងមានកាពិបុក និង ខ្ទិះដូងជាដើម)

- ហហ្មុកត្រីរស់ , ហហ្មុកត្រីអណ្តែងដាក់ស្លឹកញ

- កុំប្រើថា: អាម៉ុក (ទំ.១៥១២)

៣១-ហ្មត់ចត់ (ស្អាត , បរិសុទ្ធ , ប្រពៃ , ឥតមន្ទិល)

- មនុស្សហ្មត់ចត់ , ធ្វើការហ្មត់ចត់
- សរសេរជា ម៉ត់ចត់ ក៏មាន តែមិនសូវប្រើទេ (ទំ.១៥៣៩)

៣២-អនុញ្ញាត (យល់ព្រម , បើកឱកាសឱ្យ)

- រដ្ឋាភិបាលបានអនុញ្ញាតឱ្យធ្វើការនោះហើយ
- កុំសរសេរជា: អនុញ្ញាតិ (ព្រោះគ្មានពាក្យនេះទេ) (ទំ.១៦២១)

៣៣-អាលម្កាយ (អ្នកចាប់ពស់ , អ្នកចេះសិល្បវិទ្យាចាប់ពស់ , ហ្មពស់)

- កុំប្រើថា: អាយលម្កាយ (ទំ.១៧៥២)

៣៤-អាវ និង សំពត់ (អាវប្រុស , អាវស្រី , សំពត់មួយអាវ)

- គួរកុំនិយាយថា: លុយតិចពេកទិញកំណាត់មួយអាវមិនបាន
- គួរនិយាយថា: ប្រាក់តិចពេកទិញសំពត់មួយអាវមិនបាន
- គឺកុំប្រើពាក្យ លុយ និងពាក្យ កំណាត់ ព្រោះជាពាក្យទាប
  (កំណាត់ជូតក្តារ , កំណាត់ជូតជើង)នាំឱ្យទ័លក្រ ឱ្យថយ
  ថោក ឱ្យអាប់ឱន ឱ្យទន់ទាប ឱ្យខ្វះខាត ឱ្យជាសម្តីអភ័ព្វ
  ដូចមាត់ថា) (ទំ.១៤២២-១៧៥៣)

៣៥-ឥណ្ឌា (ឈ្មោះភូមិប្រទេសមួយប៉ែកធំទូលាយក្នុងទ្វីបអាស៊ីដែលក្នុងបុរាណសម័យ
ហៅថា សិន្ធព ឬ សិន្ធុ ហៅក្លាយថា ហិណ្ឌូ តមកទៀតហៅ
ឥណ្ឌូ អង់គ្លេសហៅប្រទេសនោះថា ឥណ្ឌា

- កុំសរសេរជា: ឥណ្ឌៀ (ទំ.១៧៦៤)

៣៦-អ៊ីចឹង (យ៉ាងហ្នឹង , ដូចហ្នឹង)

- ធ្វើអ៊ីចឹងមិនត្រូវទេ ធ្វើអ៊ីចេះវិញ
- កុំប្រើថា: អញ្ចឹង (ទំ.១៧៧៥)

៣៧-អ៊ីចុង (អ៊ីចុះ , ដច្នោះ)

- អុំ!អ៊ីចុងទេឬ? ធ្វើអ៊ីចុងមិនកើត
- កុំប្រើថា: អញ្ចុង (ទំ.១៧៧៥)

៣៨-ឱ្យ (រាប់ថាជា អញ្ញត្រសព្ទ ឃើញប្រើយូរហើយតាំងពីសម័យសោធរបុរៈ
មហានគរ ប្រើជាប់ដរាបមកពុំដែលកែប្រែទេ ត្រូវទុកដូចដើម ។
អញ , អ្នក , នេះ , នោះ , ហោង ក៏រាប់ថាជា
អញ្ញត្រសព្ទដែរ)

- កុំប្រើថា: ឱយ ឬ អោយ (ទំ.១៧៧៩-១៨៤៤)

៣៩-អំណរ (សេចក្តីអរ)

- កុំប្រើថា: សេចក្តីអំណរ , ការអំណរ (ទំ.១៨៤៧)

៤០-អំណោយ (ការឱ្យ , អ្វីៗដែលឱ្យ)

- កុំប្រើថា: សេចក្តីអំណោយ , ការអំណោយ , របស់អំណោយ
- ត្រូវប្រើថា: របស់ជាអំណោយ (ទំ.១៨៤៨)

៤១-អំនួត (ការពោលអួត , សម្តីអួត)

- កុំប្រើថា: សេចក្តីអំនួត (ទំ.១៨៤៨)

៤២-អំពល់ (កង្វល់ , សេចក្តីខ្វល់ចិត្ត , ដំណើរដែលនាំឱ្យមានរវល់ខ្វល់ចិត្ត)

កុំប្រើថា: សេចក្តីអំពល់ , ការអំពល់ (ទំ.១៨៥០)